00523600

C26/9/13.1

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*******

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានពន្ធនាគារ**

**មន្ទីរឃុំឃាំងនៃ អ.វ.ត.ក**

**លេខ..៤៣../១០......មឃ**

============

ភ្នំពេញថ្ងៃ,ទី៣០ ខែមេសា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
31/05/2010
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## សូមគោរពជូន

**ឯកឧត្តមប្រធានអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក**

**<u>កម្មវត្ថុ</u>** : ស្តីពីជនត្រូវចោទ **ខៀវ សំផន** ស្នើសុំលើកពេលឡើងសវនាការ។

**<u>យោង</u>** : ដីកាបង្គាប់លេខ C២៦/៩/១១ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ របស់ឯកឧត្តម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទមានកិត្តិយស សូមជំរាបជូនឯកឧត្តមប្រធានអង្គបុរេជំនុំជម្រះមេត្តាជ្រាបថា ៖ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ មន្ទីរឃុំឃាំងបានទទួលដីកាបង្គាប់ឲ្យនាំជនត្រូវចោទទៅចំពោះមុខតុលាការចំនួន ០១ច្បាប់ មានពីរភាសារ(ភាសារខ្មែរ ភាសារអង់គ្លេស) រហូតមកដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ វេលាម៉ោង ០៩.១៥ នាទី ជនជាប់ចោទ ខៀវ សំផន បានស្នើសុំមកមន្ទីរឃុំឃាំង ដើម្បីលើកពេលឡើងសវនាការទៅថ្ងៃក្រោយដោយមូលហេតុ មេធាវីរបស់ជនជាប់ចោទពុំមានវត្តមាននៅក្នុងថ្ងៃសវនាការ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមឯកឧត្តមប្រធានអង្គបុរេជំនុំជម្រះមេត្តាពិនិត្យ និងសំរេចតាមការគួរ។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

**ប្រធានមន្ទីរឃុំឃាំង**

ម៉ៅ_សុភារម្យ

***<u>សេចក្តីបញ្ជាក់</u>:***

ខ្ញុំបាទឈ្មោះ ខៀវ សំផន ស្នើសុំលើក ពេល
ឡើងសវនាការថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០។

*មន្ទីរឃុំឃាំង,ថ្ងៃទី ខែ ឆ្នាំ២០១០*

**ស្នាមមេដៃស្តាំ**



<u>ចម្លងជូន៖</u>
- *អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ*
- *ឯកឧត្តមអគ្គនាយករងទទួលផែនប្រតិបត្តិ*
- *ផ្នែកសន្តិសុខកម្ពុជានៃ អ.វ.ត.ក*
- *ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក*
- *ផ្នែកគ្រប់គ្រងតុលាការនៃ អ.វ.ត.ក*
- *មន្ត្រីទំនាក់ទំនងមន្ទីរឃុំឃាំង*
- *ឯកសារ កាលប្បវត្តិ*

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
31/05/2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun